# មជ្ឈមណ្ឌលឯកសារកម្ពុជា

ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២

លោក អ៊ីង បូរ៉ាត
ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ

លោកប្រធានមន្ទីរជាមេត្រី !

ខ្ញុំបាទសូមជម្រាប លោកប្រធានមន្ទីរឲ្យបានជ្រាបថា កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដាក់ និងសម្ពោធពាក្យស្លោករួចរាល់នៅវិទ្យាល័យក្នុងរាជធានីភ្នំពេញ ចំនួន១០ ខេត្តកណ្តាល ចំនួន១ ខេត្តកំពត ចំនួន១ ខេត្តមណ្ឌលគិរី ចំនួន១ ខេត្តសៀមរាប ចំនួន១ និងខេត្តប៉ៃលិន ចំនួន១ ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងតំណាងប្រធានមន្ទីរអប់រំ យុវជន និងកីឡា ។

ដោយយោងតាមលិខិតរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ២២២៤អយក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ អនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្សព្វផ្សាយពាក្យស្លោកចំនួនពីរនៅតាមសាលាមធ្យមសិក្សាបំណេះទូទៅ ខ្ញុំបាទស្នើសុំការអនុញ្ញាតធ្វើពាក្យស្លោកទាំងពីរ នៅវិទ្យាល័យទូទាំងខេត្តឧត្តរមានជ័យ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមន្ទីរ អនុញ្ញាតឲ្យខ្ញុំបាទធ្វើពាក្យស្លោកខាងលើនៅវិទ្យាល័យក្នុងខេត្តឧត្តរមានជ័យ ដោយអនុគ្រោះ ។

សូមលោកប្រធានមន្ទីរទទួលការគោរពពីខ្ញុំ ។

ឆាំង យុ
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ: ៦៣៥ អយកឧ.មចទ
បានឃើញ និងអនុញ្ញាត
ឱ្យបិទផ្សាយ ពាក្យស្លោកទាំងពីរ នៅវិទ្យាល័យ
ទូទាំងខេត្តឧត្តរមានជ័យ ។
ឧត្តរមានជ័យ, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**អ៊ីង បូរ៉ាត់**